# ករណីយកិច្ច

នៃ

## ចៅអធិការ អនុគណ និង មេគណ

ក្នុងព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៧

ផ្សាយចេញពី

**www.haotrai.com**

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ករណីយកិច្ច

នៃ

## ចៅអធិការ អនុគណ និង មេគណ

ក្នុងព្រះរាជាណាចក្រកម្ពុជា

តាមសេចក្តីសម្រេច

នៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទី១៧-១៨

ដោយក្រសួងធម្មការ បានឃើញហើយយល់ព្រមផង

បោះពុម្ពឡើងវិញ ចំនួន ៥.០០០ ក្បាល

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៣៧ គ.ស ១៩៩៤

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាពិភពលោកជប៉ុន ស្តីពីសាសនា និងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this book would contribute to the Friendship with Cambodian people and their religious and cultural preservation.

កម្ពុជា

ក្រសួងព្រះសង្ឃរាជ

គណៈមហានិកាយនៃកម្ពុជា

លេខ : ៣៣ គសរ.វ

ព្រះសង្ឃប្រកាស

# សម្តេចព្រះមហាសុមេធាធិបតី
# ព្រះសង្ឃរាជគណៈមហានិកាយនៃកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ១៩៨១ ស្តីពីការតែងតាំងសម្តេចព្រះសង្ឃរាជគណៈមហានិកាយ នៃកម្ពុជា,

- បានឃើញ ព្រះសង្ឃដីកាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយ លេខ ៤៥ ពក. ចុះថ្ងៃព្រហស្បតិ៍ ៥ រោច ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥០៤ គឺថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៦២ ស្តីពីការសុំអោយព្រះមេគណ អនុគណ ចៅអធិការគ្រប់វត្ត ក្នុងព្រះរាជាណាចក្រ ប្រតិបត្តិតាមករណីយកិច្ចដែលអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃ ក្នុងឆ្នាំ១៩៦២ បាន អនុម័តហើយ,

- ដោយយោងអនុលោមតាមបញ្ញត្តិរបស់អង្គប្រជុំនៃគណៈសង្ឃថេរសភា ពីថ្ងៃសុក្រ ទី២០ ខែសីហា ១៩៨៣ នៅវត្តឧណ្ណាលោម មានយោបល់ព្រមគ្នាថា ច្បាប់ ចែងអំពីករណីយកិច្ច សំរាប់ចៅអធិការ អនុគណ និងមេគណ ដែលអនុសំវច្ឆរមហាសន្និបាតទី១៨ នៃមន្ត្រីសង្ឃ ពីឆ្នាំ១៩៦២ បានអនុម័តហើយនោះ គប្បីអនុវត្តបន្តទៅទៀត ព្រោះជាករណីយកិច្ច ត្រូវបំពេញជាការចាំបាច់,

- យោលទៅលើការចាំបាច់ ក្នុងការពង្រឹងការងារគ្រប់គ្រងផ្នែកពុទ្ធ-សាសនានៅកម្ពុជា នាបច្ចុប្បន្ន,

## សម្រេច

**ប្រការ ១** : ទទួលស្គាល់ករណីយកិច្ចនៃចៅអធិការ អនុគណ មេគណ ដែលអនុសំវច្ឆរមហាសន្និបាតទី១៨ នៃមន្ត្រីសង្ឃ សំរាប់ឆ្នាំ១៩៩២ បានសំរេចហើយនោះ ទុកជាករណីយកិច្ចធរមាន ដើម្បីបន្តអនុវត្តសំរាប់គ្រប់គ្រងកិច្ចការពុទ្ធសាសនា តទៅ ។

**ប្រការ ២** : ចៅអធិការ អនុគណ មេគណ គ្រប់ខេត្ត-ក្រុង ស្រុក ខ័ណ្ឌ និងគ្រប់វត្ត មានភារកិច្ចប្រតិបត្តិករណីយកិច្ចនេះ តាមមុខការ និងមុខនាទីរបស់ខ្លួន ។

**ប្រការ ៣** : ព្រះសង្ឃប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

វត្តឧណ្ណាលោម, ថ្ងៃសុក្រ ៦រោច ខែស្រាពណ៍ ឆ្នាំរកា បញ្ចស័ក

ព.ស. [illegible] ខែកញ្ញា ឆ្នាំ ១៩៩៣

[illegible]ទិបតី

[illegible]នៃកម្ពុជា

[illegible]

( [illegible]ម្ពោជ្ឈង្គិកោ )

លេខ ៧០_៩៣ កធស

បានឃើញ និងយល់ព្រមផង

ភ្នំពេញ, ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៣

រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា

ហត្ថលេខា និងត្រា : ឈឹម សៀកឡេង

# ព្រះសង្ឃដីកា

ស្ដីពី

## ករណីយកិច្ច តួនាទី និងមុខការ

## របស់ចៅអធិការ - អនុគណ - មេគណ

ព្រះរាជាណាចក្រកម្ពុជា

លេខ ៤៥ ណ.

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ក្រសួងព្រះសង្ឃនាយក គណៈមហានិកាយ

ព្រះសង្ឃដីកា

ថ្ងៃ៥ ៩រោច ៤ ឆ្នាំឆ្លូវត្រីស័ក ព.ស.២៥០៤ គឺថ្ងៃទី២៩ មីនា គ.ស.១៩៦២

# សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ

មកដល់ព្រះមេគណ - អនុគណ និង ចៅអធិការគ្រប់វត្តក្នុងព្រះរាជាណាចក្រ ;

កម្មវត្ថុ ៖ ការសុំឲ្យព្រះមេគណ-អនុគណ-ចៅអធិការ ទទួលប្រតិបត្តិតាមករណីយកិច្ច ដែលអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃបានអនុម័តហើយ ។

រឿងនេះ កាលអនុសំវច្ឆរមហាសន្និបាតទី១៧ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៦១ បានមានយោបល់ព្រមគ្នាថា ត្រូវបង្កើតឲ្យមានច្បាប់ចែងអំពីករណីយកិច្ចសម្រាប់ចៅអធិការ - អនុគណ - មេគណ ប្រតិបត្តិដើម្បីឲ្យបានស្គាល់ច្បាស់នូវនាទី ឬមុខការរបស់ខ្លួន ដែលជាករណីយកិច្ចត្រូវបំពេញជាការចាំបាច់ ។

សម្តេចជាសង្ឃនាយក បានរំពឹងមើលដោយវែងឆ្ងាយទៅ ឃើញថា បច្ចុប្បន្នកាលនេះ អស់លោកមេគណ-អនុគណ និងចៅអធិការភាគច្រើន បានយកចិត្តទុកដាក់រៀបចំវត្តអារាមរបស់ខ្លួនឲ្យប្រព្រឹត្តទៅកាន់សេចក្តីចំរើនរុងរឿងតាមកាលសម័យ ព្រមទាំងប្រឹតប្រៀនវត្តប្រតិបត្តិទាំងពួង តាមនាទីរបស់ខ្លួនឲ្យសមរម្យទៅតាមវិនយបញ្ញត្តិគួរដល់ការហើយ ប៉ុន្តែ មានលោកមេគណ-អនុគណ និងចៅអធិការខ្លះ ពុំទាន់ស្គាល់មុខការនាទីរបស់ខ្លួនដោយសព្វគ្រប់នៅឡើយទេ ។

អាស្រ័យហេតុនេះហើយ បានជាក្រសួងធម្មការបានតែងតាំងគណៈកម្មការ ១ ក្រុមតាមលិខិតបង្គាប់ការលេខ ១៩ កធ និងលេខ ៩៣ កធ. ចុះថ្ងៃទី ១៦ កុម្ភៈ និងថ្ងៃទី ២២ សីហា ១៩៦១ គណៈកម្មការនោះមានមហាថេរជាសមាជិកនៃថេរសភាខ្លះ ជាសាស្ត្រាចារ្យសាលាពុទ្ធិកវិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យខ្លះ និងដែលជាបុគ្គលិកនៅក្រសួងធម្មការខ្លះ ដែលមានសមត្ថភាពបរិបូណ៌ឲ្យព្រាងករណីយកិច្ចលោកមេគណ-អនុគណ និងចៅអធិការ ហើយឲ្យគណៈកម្មការដដែលនេះពិនិត្យកែសម្រួលអត្ថបទនេះច្រើនលើកច្រើនគ្រា រួចហើយបានដាក់ប្រគេនមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៦២ ពិភាក្សាម្តងទៀត មហាសន្និបាតបានអនុម័តជាឯកច្ឆ័ន្ទ ដោយយល់ឃើញថាអត្ថបទនេះគួរដល់ការហើយ ។

# ករណីយកិច្ច

នៃ

# លោកចៅអធិការវត្ត

## ករណីយកិច្ច

# នៃលោកចៅអធិការវត្ត

ភិក្ខុដែលបានទទួលការតែងតាំងជាចៅអធិការពេញទី តាមព្រះសង្ឃប្រកាសលេខ ៤ ចុះថ្ងៃទី ៨ មេសា ១៩៦៩ រួចហើយ ត្រូវបំពេញករណីយកិច្ចរបស់ខ្លួនដូចតទៅនេះ :

- ការថែទាំវត្តអារាម
- ការថែទាំរក្សាវត្ថុជាគ្រុភណ្ឌ
- ការបំពេញនាយកធម៌ឲ្យមាននៅក្នុងខ្លួនព្រមទាំងឲ្យចេះបាតិមោក្ខបាលីផង
- ការគ្រប់គ្រងភិក្ខុ-សាមណេរនិងកុមារ ដែលអាស្រ័យនៅក្នុងវត្ត
- ការទាក់ទងនឹងពុទ្ធបរិស័ទជើងវត្ត
- ការទាក់ទងនឹងគណៈសង្ឃ

## ១- អំពីការថែទាំវត្តអារាម

លោកចៅអធិការដែលត្រូវថែទាំវត្តអារាមនោះ ត្រូវប្រតិបត្តិដូច្នេះគឺ:

ក- ត្រូវដឹងទំហំទីដីវត្តជុំវិញ ហើយធ្វើកំពែងឬរបង ដើម្បីការពារកុំឲ្យទីដីវត្តនោះខ្ចាត់ខ្ចាយ ឬធ្លាក់ទៅជាសម្បត្តិរបស់អ្នកណាមួយ ព្រោះ

ទីដីនោះជាគរុភណ្ឌរបស់សង្ឃ - ប្រសិនបើលោកចៅអធិការពុំដឹងប្រាកដនូវទីដីទីធ្លាព្រំដែនរបស់វត្តទេ ត្រូវចាត់ការសួរដល់ពួកអ្នកដែលមានទីដីជាប់នឹងដីវត្ត បើសង្ស័យក្រែងទីដីនោះបានកាត់ខ្វះធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃអ្នកដែលនៅជុំវិញវត្ត ត្រូវឲ្យអាចារ្យវត្តប្ដឹងទៅមេឃុំ សូមឲ្យចាត់ការប្ដឹងទៅក្រុមសុរិយោដី ដើម្បីឲ្យគេមកវាស់វែងកំណត់ព្រំដែនឲ្យច្បាស់លាស់ ហើយសឹមធ្វើកំពែងឬរបងព័ទ្ធជុំវិញតទៅ ។

១– ត្រូវចាត់ការរៀបចំទីវត្តទាំងមូលឲ្យបានស្អាតបាត សមជាទីប្រតិស្ឋានព្រះពុទ្ធសាសនា គឺត្រូវរៀបចំទីវិហារ - កុដិ - សាលាបុណ្យ សាលាសិក្សា-កប្បិយកុដិ-វច្ចកុដិ-ទីសួនច្បារ ទីងស្រះអណ្ដូង ដែលជាទីសេនាសនៈឬជាវត្ថុដែលត្រូវតែឲ្យមានក្នុងទីវត្តជាការចាំបាច់ ត្រូវរៀបចំឲ្យសមរម្យឲ្យមានរបៀបរៀបរយល្អ កុំឲ្យប្រផេងប្រផាងតាមតែអ្នកតាំងខ្លួន ជាពិសេសគឺត្រូវរៀបចំធ្វើឲ្យស្អាតគ្រប់ទីកន្លែង ។

## ២– អំពីការថែទាំរក្សាវត្ថុជាគរុភណ្ឌ

លោកចៅអធិការដែលត្រូវថែទាំរក្សាវត្ថុជាគរុភណ្ឌនោះ ត្រូវប្រតិបត្តិដូចនេះគឺ :

ក– លោកចៅអធិការត្រូវសិក្សាឲ្យបានចេះច្បាប់គរុភណ្ឌជាមុន ឲ្យដឹងថាវត្ថុណាខ្លះជាគរុភណ្ឌ ។ នោះជារបស់សង្ឃ ឬ ជារបស់បុគ្គល

គរុភណ្ឌនោះដែលកើតមានឡើង កើតឡើងយ៉ាងណា ការរក្សាគរុភណ្ឌនោះត្រូវធ្វើដូចម្តេច ? គរុភណ្ឌនោះបែកធ្លាយបានឬទេ ?

២- លោកចៅអធិការ កាលបើដឹងច្បាប់គរុភណ្ឌនេះច្បាស់លាស់ហើយ ទើបអាចនឹងចាត់ការថែទាំរក្សាវត្ថុជាគរុភណ្ឌរបស់សង្ឃ ឲ្យគង់នៅបានដោយប្រពៃ - បើមិនចេះមិនដឹងច្បាប់គរុភណ្ឌនេះទេ មិនអាចនឹងគ្រប់គ្រងវត្តអារាម ដោយប្រាសចាកទោសបានឡើយ ។

( ការគ្រប់គ្រងព្រមទាំងការរក្សាគរុភណ្ឌនេះ ត្រូវសិក្សាឲ្យចេះជាមុនទើបអាចរក្សាបាន )

## ៣- ការបំពេញនាយកធម៌ឲ្យមាននៅក្នុងខ្លួនព្រមទាំងឲ្យចេះភិក្ខុបាតិមោក្ខបាលីផង

លោកចៅអធិការវត្តនីមួយ ៗ ត្រូវឲ្យមាននាយកធម៌ប្រចាំនៅក្នុងខ្លួន គឺសន្តានចិត្តជានិច្ច ព្រោះនាយកធម៌នេះអាចនឹងដឹកនាំចៅអធិការឲ្យមានសមត្ថភាពអាចនឹងបំពេញឋានៈរបស់ខ្លួនជាចៅអធិការបានពេញទី ហើយគាប់ប្រសើររុងរឿងក្នុងមជ្ឈដ្ឋាននៃព្រះសង្ឃក្នុងវត្តផង ក្នុងមជ្ឈដ្ឋាននៃព្រះសង្ឃទូទៅផង ។

ឯនាយកធម៌នោះ មានសេចក្តីអធិប្បាយដោយសង្ខេប ដូចមានខ្ញាស់ជាប់មកជាមួយនេះស្រាប់ ក្រៅពីនាយកធម៌នេះ គួរតែឲ្យចេះភិក្ខុបាតិមោក្ខបាលីផង ។

## ៤- អំពីការត្រួតត្រាភិក្ខុ - សាមណេរនិងកុមារដែលអាស្រ័យនៅក្នុងវត្ត

លោកចៅអធិការ ដែលត្រូវត្រួតត្រាភិក្ខុ - សាមណេរនិងកុមារដែលអាស្រ័យនៅក្នុងវត្តនោះ ត្រូវប្រតិបត្តិដូចនេះគឺ:

ក- ត្រូវត្រួតត្រាភិក្ខុ-សាមណេរក្នុងវត្ត ឲ្យខំសិក្សារៀនសូត្រឲ្យបានចេះដឹងវិន័យជាច្បាប់ព្រះពុទ្ធសាសនា ព្រមទាំងឲ្យគោរពប្រតិបត្តិតាមច្បាប់វិន័យដែលបានចេះដឹងហើយនោះផង ។

ខ- បើអាចធ្វើបាន ត្រូវបង្កើតឲ្យមានសាលាធម្មវិន័យ ឬ សាលាពុទ្ធិកបឋមសិក្សា ឬបង្កើតឲ្យមានសាលាទាំងពីរនេះ ប្រសិនបើមានភិក្ខុ-សាមណេរច្រើន ទាំងពុទ្ធបរិស័ទជើងវត្តក៏មានសមត្ថភាព អាចជួយឧបត្ថម្ភភិក្ខុ-សាមណេរទាំងនោះបាន ។

គ- ត្រូវចាត់ការរៀបចំបង្កើតឲ្យមានកម្មវិធី និងកាលវិភាគសម្រាប់ភិក្ខុ-សាមណេរគោរពប្រតិបត្តិតាមក្នុងពេលថ្ងៃនិងក្នុងពេលយប់ គឺតាំងពីព្រឹកដល់ល្ងាច រហូតដល់ពេលយប់ ភិក្ខុ-សាមណេរត្រូវសិក្សា ឬត្រូវសូត្រធម៌នមស្ការព្រះរតនត្រ័យ ឬត្រូវបំពេញកិច្ចយ៉ាងណា ក្នុងពេលណា ដើម្បីឲ្យភិក្ខុ-សាមណេរងាយប្រតិបត្តិតាម ។

ឃ- ត្រូវឧស្សាហ៍ប្រជុំភិក្ខុ-សាមណេរឲ្យបានរឿយៗ បើយ៉ាងតិចណាស់ក្នុងមួយខែ ២ ដង ។ ការប្រជុំនោះត្រូវនិយាយរំលឹកដាស់តឿន

ភិក្ខុ-សាមណេរ ចំពោះការសិក្សា-ការគោរពប្រតិបត្តិតាមពុទ្ធោវាទ និងការទូន្មានប្រៀនប្រដៅឲ្យមានសាមគ្គីធម៌រវាងគ្នានឹងគ្នា ព្រមទាំងប្រាប់ទោសនៃការឈ្លោះប្រកែកបែកបាក់គ្នា និងគុណនៃការរួបរួមគ្នា ។ កិច្ចនេះ បើលោកចៅអធិការមានធុរៈមិនអាចធ្វើជាប្រធានក្នុងការប្រជុំបានទេ ត្រូវឲ្យគ្រូសូត្រស្តាំ ឬគ្រូសូត្រឆ្វេងជំនួស ។

ក្រៅពីភិក្ខុ-សាមណេរមានកុមារតើយុវជន ដែលមកសំណាក់អាស្រ័យនៅក្នុងវត្ត តាមតែកុមារប្រភេទណាក៏ដោយ លោកចៅអធិការត្រូវយកចិត្តទុកដាក់ចាត់ការរៀបចំដឹកនាំ ឬអប់រំយុវជនទាំងនោះ ឲ្យបានស្គាល់ព្រះពុទ្ធសាសនា ឬឲ្យបានចេះដឹងធម៌អាថ៌ខ្លះ ក្នុងព្រះពុទ្ធសាសនា ។ ចំពោះពួកកុមារទាំងនោះ លោកចៅអធិការត្រូវចាត់ការជាពិសេស ដូចតទៅនេះគឺ:

ក- ត្រូវជ្រើសរើសយកថ្ងៃនិងពេលវេលាណា ដែលពួកយុវជនមានឱកាសល្មមឲ្យមកប្រជុំបាន ក្នុងមួយសប្តាហ៍ ១ ដង ឬ ២ ដង ។ ក្នុងការប្រជុំយុវជនទាំងនោះ ត្រូវបង្ហាត់ឲ្យចេះសូត្រធម៌នមស្ការព្រះរតនត្រ័យ យ៉ាងសង្ខេប ព្រមទាំងបង្រៀនពន្យល់ឲ្យចេះលទ្ធិព្រះពុទ្ធសាសនាខ្លះៗ តាមសៀវភៅ "ការសិក្សាព្រះពុទ្ធសាសនាសម្រាប់យុវជន" ដែលសម្តេចព្រះសង្ឃនាយកនឹងរៀបចំក្នុងពេលខាងមុខនេះ ។

ខ– ក្នុងពេលដែលត្រូវប្រជុំពួកយុវជនខាងលើនេះ ប្រសិនបើមានយុវជននៅក្នុងទីផ្សេង ៗ ឬពួកឧបាសក-ឧបាសិកានៅក្នុងទីផ្សេងៗ ត្រូវការមកសូមសិក្សារួមជាមួយផង លោកចៅអធិការត្រូវអនុញ្ញាតឲ្យតាមប្រាថ្នា ។

គ– លោកចៅអធិការ ដែលបានចាត់ការដូចខាងលើនេះ ត្រូវតាំងចិត្តអនុគ្រោះចំពោះយុវជន ដោយគោរពចំពោះព្រះពុទ្ធសាសនា មិនត្រូវអង្គាសយោស្នាចតុប្បច្ច័យ អំពីយុវជនទាំងនោះឡើយ ។ បើលោកចៅអធិការមានសមត្ថភាពគ្រប់គ្រាន់ គួរតែលៃលកចែកសៀវភៅសរសេរនិងសៀវភៅសម្រាប់សិក្សាដល់យុវជនទាំងនោះផង ដោយសេចក្ដីអនុគ្រោះ ។

## ៥– អំពីការត្រូវទាក់ទងនឹងពុទ្ធបរិស័ទជើងវត្ត

លោកចៅអធិការដែលត្រូវទាក់ទងនឹងពុទ្ធបរិស័ទជើងវត្តនោះ ត្រូវប្រតិបត្តិដូចតទៅនេះគឺ :

– ត្រូវដឹងថាវត្តអារាមនីមួយ ៗ ដែលកើតឡើង ដោយអាស្រ័យនឹងពួកឧបាសក - សិកា ជើងវត្តមានសទ្ធាជ្រះថ្លា បរិច្ចាគទ្រព្យ បរិច្ចាគ-កម្លាំងរួបរួមគ្នា ទើបអាចកសាងឡើងបាន ។ ម្យ៉ាងទៀត ត្រូវដឹងថាសង្ឃដែលអាស្រ័យនៅក្នុងវត្តនីមួយ ៗ ដែលមានជីវភាពប្រព្រឹត្តទៅបាន ក៏គោងអាស្រ័យពឹងផ្អែកទៅលើពួកឧបាសក-សិកាជើងវត្តជាពុទ្ធបរិស័ទជួយ

ផ្តល់បច្ច័យ ។ បើគេមានពុទ្ធបរិស័ទដើរវត្តទេ ឬមានដែរ ប៉ុន្តែគេអត់មានសទ្ធាជ្រះថ្លាចំពោះព្រះសង្ឃគង់វត្តនោះ សង្ឃក៏មិនអាចនឹងអាស្រ័យនៅគង់វត្តបានឡើយ កាលបើដឹងដូចខាងលើនេះហើយ ត្រូវទាក់ទងនឹងពុទ្ធ-បរិស័ទដើរវត្ត ឲ្យមានការប្រាស្រ័យនិងការអនុគ្រោះតាមផ្លូវធម៌ដូចតទៅនេះគឺ:

- ត្រូវជួយដឹកនាំពុទ្ធបរិស័ទឲ្យស្គាល់ផ្លូវអាក្រក់ដែលនាំឲ្យបានទុក្ខព្រួយ និងផ្លូវល្អដែលនាំឲ្យបានសុខ - ចំរើន ព្រមទាំងដឹកនាំឲ្យលះបង់អំពើអាក្រក់ ប្រព្រឹត្តធ្វើអំពើល្អឡើង ។

- ត្រូវជួយបង្ហាត់បង្រៀនពួកពុទ្ធបរិស័ទ ឲ្យចេះដឹងធម៌អាថ៌ណាដែលមិនទាន់បានចេះដឹង ។

- ត្រូវដឹងទុក្ខធុរៈរបស់ពួកពុទ្ធបរិស័ទដើរវត្ត ហើយត្រូវជួយដោះទុក្ខធុរៈនោះ ដោយមធ្យោបាយដ៏សមរម្យតាមច្បាប់ព្រះពុទ្ធសាសនា ។

- ត្រូវតាំងឲ្យមានគណៈកម្មការគ្រហស្ថសម្រាប់វត្តមួយក្រុមសម្រាប់ជួយកិច្ចការវត្ត តាមព្រះសង្ឃប្រកាសលេខ ៨ ចុះថ្ងៃទី ២ មេសា ១៩៥៤

- បើពុទ្ធបរិស័ទណាមួយ ភ្លាត់គំនិតធ្លាក់ខ្លួនទៅជាមិច្ឆាទិដ្ឋិកបុគ្គល ត្រូវជួយពន្យល់ដឹកនាំយិតយោងពុទ្ធបរិស័ទនោះ ឲ្យភ្ញាក់ខ្លួនមានស្មារតីឲ្យបានទៅជាសម្មាទិដ្ឋិកបុគ្គលឡើងវិញ ។

ក្រៅពីពួកពុទ្ធបរិស័ទជើងវត្តខាងលើនេះ ចំពោះពួកពុទ្ធបរិស័ទទូទៅ លោកចៅអធិការវត្តនីមួយៗ ត្រូវមានភារៈជាអ្នកពន្យល់ណែនាំ ឲ្យងាកចេញពីផ្លូវខុស បែរឆ្ពោះទៅរកផ្លូវត្រូវ តាមមាគ៌ានៃព្រះពុទ្ធ-សាសនាផង ។

## ៦- ការទាក់ទងនឹងគណៈសង្ឃ

លោកចៅអធិការដែលមានការទាក់ទងនឹងគណៈសង្ឃនោះ ត្រូវប្រតិបត្តិដូចនេះគឺ :

ក- បើក្នុងវត្តមានភិក្ខុ-សាមណេរ កើតវិវាទរវាងគ្នានិងគ្នា លោកចៅ-អធិការត្រូវហៅមកជំនុំជំរះផ្សះផ្សាអោយខ្លួនឯង បើអធិករណ៍នោះមិនស្ងប់ ត្រូវចាត់ការបង្កើតក្រុមជំនុំសង្ឃមួយក្នុងវត្តឲ្យយកគ្រូសូត្រស្តាំ ឬឆ្វេងធ្វើជាប្រធាន ហៅថាគណៈសង្ឃសម្រាប់វត្ត បើគណៈសង្ឃនោះ លោកចៅអធិការបានតែងតាំងរួចស្រេចពីមុនមកស្រាប់ហើយ ក៏ជាការប្រពៃ គណៈសង្ឃនេះ ត្រូវជំនុំជំរះហើយផ្សះផ្សាគូវិវាទនោះឲ្យបានសះជានិងគ្នា បើនៅតែមិនសម្រេចទៀត ត្រូវបញ្ជូនរឿងនោះទៅគណៈសង្ឃសាលាអនុគណ ។ នឹងជំនុំជំរះតទៅទៀត ។

ខ- បើមានកិច្ចការដទៃក្រៅពីអធិករណ៍ ដូចជាការសូមបង្កើតឲ្យមានសាលាពុទ្ធិកបឋមសិក្សាក្នុងវត្តក្តី ការសូមច្បាប់រុះរើវិហារចាស់

ហើយសាងសង់ជាថ្មី ។ល។ កិច្ចទាំងអស់នេះ ក៏ត្រូវទៅទាក់ទងនឹងគណៈសង្ឃនៅសាលាអនុគណផងដែរ ។

គ- ក្រៅពីនេះ បើលោកអនុគណមានការប្រជុំសង្ឃក្នុងស្រុក ដែលលោកអនុគណជាអ្នកត្រួតត្រា ហើយទាក់ការនិមន្តលោកចៅអធិការវត្តទៅប្រជុំ លោកចៅអធិការត្រូវតែនិមន្តទៅជួបជុំ មិនត្រូវគេចវេះទេ ព្រោះគណៈសង្ឃសាលាអនុគណក្នុងស្រុកនីមួយ ៗ មានអំណាចត្រួតត្រាទៅលើវត្តទាំងអស់ដែលនៅក្នុងស្រុក ។

ការទាក់ទងនឹងគណៈសង្ឃនេះ មិនមែនត្រូវមានញឹកញាប់ទេ យូរៗមានម្តង ៗ ប៉ុន្តែបើលោកចៅអធិការអាចទាក់ទងញឹកញាប់បាន ក៏រឹងរឹតតែនាំឲ្យបានស្រួល គឺស្រួលដោយមានការរួបរួមគ្នាជាមួយនឹងគណៈសង្ឃសាលាអនុគណកាន់តែជិតស្និទ្ធឡើង ។ បើមានការអ្វី ៗ ជាការលំបាក មានព្រះសង្ឃជាមិត្តកេបជួយដោះស្រាយ ឲ្យរួចពីការលំបាកដោយឆាប់រហ័ស ។

-ចប់-

# គរុភណ្ឌ ២៥ បែកជា ៥ ពួក

បញ្ចិមានិ ភិក្ខវេ អវិស្សជ្ជិយានិ ន វិស្សជ្ជេតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិស្សជ្ជិតានិបិ អវិស្សជ្ជិតានិ ហោន្តិ យោ វិស្សជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស ។

ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរលះចេញ ៥ យ៉ាងនេះ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ ។ សូម្បីលះចេញហើយក៏មិនឈ្មោះថាលះឡើយ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ ។ កតមានិ បញ្ច ។ របស់ទាំង ៥ នោះដូចម្តេច ?

១– អារាមោ អារាមវត្ថុ ឥទំ បឋមំ ។ អារាមៈគឺសួនច្បារ ១, អារាមវត្ថុគឺទីដីជាសួនច្បារ ១ នេះជារបស់មិនគួរលះចេញជាដំបូង ។

២– វិហារោ វិហារវត្ថុ ឥទំ ទុតិយំ ។ វិហារៈគឺលំនៅ១, វិហារវត្ថុគឺទីដីសម្រាប់សង់លំនៅ១ នេះជារបស់មិនគួរលះចេញជាគំរប់២ ។

៣– មញ្ចោ បីឋំ ភិសិ ពិម្ពោហនំ ឥទំ តតិយំ ។ មញ្ចៈគឺគ្រែ ១, បីឋៈគឺតាំងឬកៅអី ១, ភិសិគឺពូក ១, ពិម្ពោហនៈគឺខ្នើយ ១ នេះជារបស់មិនគួរលះចេញជាគំរប់ ៣ ។

៤– លោហកុម្ភី លោហភាណកំ លោហវារកោ

លោហកដាហំ វាសី ផរសុ កុឋារី កុទ្ទាលោ និខា-
ទនំ ឥទំ ចតុត្ថំ ។ លោហកុម្ភីគឺឆ្នាំងដែលធ្វើដោយលោហជាតិ ១, លោហភាណកៈគឺខ្ទះលោហៈ ១, លោហវារកៈគឺក្អមលោហៈ ១, លោហ-
កដាហៈគឺផើងលោហៈ ១, វាសីគឺកាំបិត ១, ផរសុគឺពូថៅ ១, កុឋារីគឺផង
ចាំង ១ កុទ្ទាលកៈគឺចប ១, និខាទនៈគឺពន្លាក ១ នេះជារបស់មិនគួរលះ
បេញជាគំរប់ ៤ ។

៥– វល្លិ វេឡុ មុញ្ជំ បព្វជំ តិណំ មត្តិកា ទារុភណ្ឌំ មត្តិកាភណ្ឌំ ឥទំ បញ្ចមំ ។ វល្លិគឺវល្លិ ១, វេឡុ គឺ ឫស្សី ១, មុញ្ជៈ គឺស្មៅដំណេកទន្សាយ១, បព្វជៈ គឺស្មៅយាប្លង១, តិណៈ គឺស្មៅធម្មតា ១, មត្តិកា គឺ ដីស្អិត ១, ទារុភណ្ឌៈគឺគ្រឿងឈើ ១, មត្តិកា-ភណ្ឌៈ គឺគ្រឿងធ្វើដោយដី ១ នេះជាវត្ថុមិនគួរលះបេញជាគំរប់ ៥ ។

នាយកធម៌

នាយកធម៌ ប្រែថា ធម៌របស់បុគ្គលអ្នកគ្រប់គ្រង ឬថា ធម៌របស់បុគ្គលអ្នកដឹកនាំអ្នកឯទៀតទៅកាន់ផ្លូវល្អ ។

នាយកធម៌មាន ៦ យ៉ាងគឺ :

១– ខមា ការអត់ធន់

២– ជាគរិយៈ ការភ្ញាក់រលឹក

៣– ឧដ្ឋានៈ ការខំប្រឹងព្យាយាម ខ្មីឃ្មាត ក្រវីនក្រវើន

៤– សំវិភាគៈ ការចែករំលែក

៥ - ទយា សេចក្តីអាណិតអាសូរ

៦-ឥក្ខណា ការរំពៃមើល ឥតបក្ខពួកបណ្តោយ

## សេចក្តីអធិប្បាយ

ធម៌ទី ១ គឺខមា "ការអត់ធន់" នេះ បើមានប្រចាំនៅក្នុងចិត្តនៃលោកចៅអធិការណា ចៅអធិការនោះតែងមានការអត់ធន់ ការធន់ទ្រាំ ទាំងផ្លូវកាយផ្លូវចិត្ត ចំពោះសេចក្តីលំបាកគ្រប់យ៉ាង ដែលកើតឡើងអំពីការងារក្តី អំពីពាក្យសំដីក្តី អំពីអ្វីៗក្តី ចេះតែមានការធន់ទ្រាំ អាចតស៊ូទៅមុខបានជាដរាបមិនថយក្រោយឡើយ ។

ធម៌ទី ២ គឺជាគរិយៈ "ការភ្ញាក់រលឹក" នេះ បើមានប្រចាំនៅក្នុងចិត្តនៃលោកចៅអធិការណា ចៅអធិការនោះតែងមានការភ្ញាក់រលឹកជានិច្ច មានការដឹងខ្លួនរលឹកឃើញនូវកិច្ចការគ្រប់យ៉ាង មិនមែនជាអ្នកច្រមក់ភ្លេចមុខភ្លេចក្រោយឡើយ ជាអ្នកមានស្មារតី មានសម្បជញ្ញៈបរិបូណ៌ ឥតធ្វេសប្រហែស ។

ធម៌ទី ៣ គឺឧដ្ឋានៈ "ការស្វះស្វែង" នេះ បើមានប្រចាំនៅក្នុងចិត្តនៃលោកចៅអធិការណា ចៅអធិការនោះឥតមានសេចក្តីខ្ជិលច្រអូសឡើយ គឺមានសេចក្តីព្យាយាម មានការខ្នះខ្នែង ប្រឹងប្រែងបំពេញមុខការគ្រប់យ៉ាង ៗ ជាអ្នកមានចិត្តគំនិតស្វះស្វែង មិនរញ្ញកថយក្រោយ ក្នុងមុខការរបស់ខ្លួន ។

ធម៌ទី ៤ គឺសំវិភាគៈ "ការចែករំលែក" នេះ បើមានប្រចាំនៅក្នុងចិត្តនៃលោកចៅអធិការណា ចៅអធិការនោះតែងមានសន្តានចិត្តល្អ ប្រាសចាកសេចក្តីកំណាញ់ប្រស្បា ជាអ្នកមានការចែករំលែកជានិច្ច គឺថា បើមានវត្ថុអ្វី ៗ មិនសន្សំទុកសម្រាប់ខ្លួនម្នាក់ឯងឡើយ តែងចែករំលែកដល់អ្នកដទៃជាដរាប ។ ការចែករំលែកនេះ មិនមែនចំពោះតែវត្ថុ ៗ ទេ ពោះបើមុខការដែលជាការៈនៃលោកចៅអធិការក្នុងវត្ត ក៏ត្រូវតែចែករំលែកដល់ភិក្ខុជាសហការី ឲ្យកាន់មុខការតាមសមត្ថភាពរបស់ខ្លួនដែរ ដើម្បីឲ្យកិច្ចការទាំងឡាយបានសម្រេចដោយប្រពៃ ។

ធម៌ទី ៥ គឺទយា "សេចក្តីករុណាអាសូរ" នេះ បើមានប្រចាំនៅក្នុងចិត្តនៃលោកចៅអធិការណា លោកចៅអធិការនោះ តែងមានសេចក្តីករុណាអាសូរដល់អ្នកដទៃ ឥតមានគំនិតគិតព្យាបាទគំនុំគុំគួនចំពោះអ្នកដទៃឡើយ តែងមានចិត្តសប្បុរសស្មោះសចំពោះអ្នកដទៃ រកបធ្វើឲ្យអ្នកដទៃត្រជាក់ចិត្តបានជាដរាប ។

ធម៌ទី ៦ គឺឥក្ខណា "ការរំពៃមើល" នេះ បើមានប្រចាំនៅក្នុងសន្តានចិត្តនៃលោកចៅអធិការណា លោកចៅអធិការនោះតែងមានការរិះគិតរំពៃមើល ចំពោះអ្នកដទៃដែលនៅក្នុងអំណាចខ្លួន ក្រែងមានកំហុសភ្ញាំងភ្ញាត់ ដោយមានបំណងចង់ឲ្យអ្នកដែលនៅ ឬដែលធ្វើការជាមួយបានប្រកបដោយគុណសម្បត្តិ ប្រាសចាកគុណវិបត្តិ ។

# ករណីយកិច្ច

នៃ

លោកអនុគណ

ករណីយកិច្ច

# នៃលោកអនុគណ

លោកចៅអធិការវត្តណាមួយ ដែលបានទទួលការតែងតាំង ជាទីអនុគណត្រឹមត្រូវតាមព្រះរាជក្រមលេខ ១៦ ន.ស. ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ១៩៤៣ រួចហើយ ត្រូវបំពេញនាទីរបស់ខ្លួនក្នុងឋានៈជាអនុគណមួយ ជាមួយនឹងគណៈសង្ឃជាសហការី ។ អនុគណនីមួយៗ មានអំណាចត្រួតត្រាព្រមទាំងចាត់ការផ្សេងៗ ខាងព្រះពុទ្ធសាសនា តែកំរិតត្រឹមតែក្នុងស្រុកនីមួយៗ របស់ខ្លួន ។ អនុគណនោះត្រូវបំពេញករណីយកិច្ចរបស់ខ្លួនដូចមានតទៅនេះគឺ :

- ការត្រួតត្រាលើលោកចៅអធិការគ្រប់វត្ត
- ការពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា
- ការធ្វើសេចក្ដីរាយការណ៍អំពីព្រះពុទ្ធសាសនា
- ការទទួលភារៈជាអ្នករម្ងាប់អធិករណ៍ខាងព្រះពុទ្ធសាសនា
- ការបំពេញនាយកធម៌ឲ្យមាននៅក្នុងខ្លួន
- ការប្រាស្រ័យទាក់ទងនឹងលោកមេគណ
- ការជួយកិច្ចការរដ្ឋដែលអាចជួយបាន ។

## ១- អំពីការត្រួតត្រាលើលោកចៅអធិការគ្រប់វត្ត

លោកអនុគណក្នុងស្រុកនីមួយ ៗ ត្រូវត្រួតត្រាលើលោកចៅអធិការគ្រប់វត្ត ក្នុងស្រុកទាំងមូល ដូចតទៅនេះ :

ក- ត្រូវរំលឹកដាស់តឿនលោកចៅអធិការគ្រប់វត្ត ឲ្យប្រតិបត្តិតាមនាទីរបស់ខ្លួន កុំឲ្យធ្វេសប្រហែស ។

ខ- ត្រូវនិមន្តលោកចៅអធិការវត្តទាំងអស់ មកប្រជុំនៅវត្តអនុគណឲ្យបាន ២ ដងក្នុងមួយឆ្នាំ គឺ៦ខែម្តង ។ ការប្រជុំនេះ នាំឲ្យមានប្រយោជន៍ច្រើនយ៉ាងគឺ :

- បានជួបមុខគ្នារឿយ ៗ ជាហេតុនាំឲ្យមានសាមគ្គីធម៌រវាងគ្នានឹងគ្នា
- បានរំលឹកដាស់តឿន ឬបានពិគ្រោះប្រឹក្សាគ្នាពីកិច្ចការផ្សេង ៗ ខាងព្រះពុទ្ធសាសនា
- បានដឹងកិច្ចការខាងព្រះពុទ្ធសាសនាដែលមានគ្រប់វត្ត ។

គ- ត្រូវធ្វើបញ្ជីវត្តទុកនៅសាលាអនុគណ ដើម្បីឲ្យដឹងថាក្នុងស្រុកដែលលោកអនុគណត្រួតត្រាមានវត្តប៉ុន្មាន ក្នុងវត្តនីមួយ ៗ មានភិក្ខុ-សាមណេរប៉ុន្មាន រូបទាំងអស់មានប៉ុន្មាន? ឯចំនួនភិក្ខុ-សាមណេរត្រូវធ្វើរាល់ឆ្នាំ ដើម្បីឲ្យដឹងថា ឆ្នាំណាមានច្រើន ឆ្នាំណាមានតិច ។

## ២- វិធីការពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា

លោកអនុគណ ត្រូវពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា ក្នុងស្រុកដែលលោកអនុគណត្រូវត្រួតត្រាដូចតទៅនេះគឺ :

ក- កិច្ចការខាងព្រះពុទ្ធសាសនា ដូចជាកិច្ចការសិក្សាក្នុងសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ ត្រូវពិនិត្យមើលឲ្យដឹងថា នៅវត្តណាមានសេចក្ដីចំរើន វត្តណាមិនចំរើន ដែលចំរើននឹងមិនចំរើន ដោយហេតុអ្វី លោកអនុគណត្រូវប្រជុំជាមួយនឹងលោកចៅអធិការវត្តនោះៗ រិះរកមធ្យោបាយដើម្បីធ្វើឲ្យការសិក្សា ដែលមិនចំរើនឲ្យបានចំរើនឡើង ការសិក្សាដែលបានចំរើនហើយ ឲ្យបានរឹងរឹតតែចំរើនជាភិយ្យោភាពឡើងទៀត ។

ខ- បើវត្តណាពុំទាន់មានការសិក្សានៅឡើយ លោកអនុគណត្រូវរកមធ្យោបាយពន្យល់ឲ្យកើតមានការសិក្សាក្នុងវត្តនោះឡើង ប្រសិនបើវត្តនោះមានភិក្ខុសង្ឃច្រើន នឹងពុទ្ធបរិស័ទជើងវត្តក៏មានច្រើនដែរ វៀរលែងតែវត្តណាមួយជាវត្តតូច មានភិក្ខុសង្ឃបន្តិចបន្តួច ទាំងពុទ្ធបរិស័ទជើងវត្តក៏មានបន្តិចបន្តួចដែរ ។

គ- ចំពោះផ្លូវប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនា ឬការរៀបចំទីវត្តអារាមក៏ឈ្មោះថា ជាកិច្ចការខាងព្រះពុទ្ធសាសនាដែរ លោកអនុគណ

ត្រូវពន្យល់ដល់លោកចៅអធិការទាំងឡាយ ឲ្យយកចិត្តទុកដាក់ដឹកនាំ កិច្ច-សាមណេរក្នុងវត្ត ឲ្យខំប្រតិបត្តិឲ្យបានត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធ-សាសនា ព្រមទាំងជួយរំលឹកលោកចៅអធិការឲ្យខំរៀបចំវត្តអារាម ឲ្យបានសមរម្យ ទាំងឲ្យបានស្អាតបាត សមជាទីកន្លែងដម្កល់ព្រះពុទ្ធសា-សនា គួរឲ្យជនទាំងឡាយចូលទៅកើតសេចក្តីជ្រះថ្លា ។

ឃ- កិច្ចការឯទៀតខាងព្រះពុទ្ធសាសនា កាលបើមានការទាក់ទងនឹងព្រះរាជរដ្ឋាភិបាល ក៏ត្រូវលោកអនុគណយកចិត្តទុកដាក់ ជួយញ៉ាំងកិច្ចការទាំងនោះឲ្យបានសម្រេច តាមសមត្ថភាពរបស់ខ្លួន ។

## ៣- អំពីការធ្វើសេចក្តីរាយការណ៍ខាងព្រះពុទ្ធសាសនា

លោកអនុគណត្រូវធ្វើសេចក្តីរាយការណ៍ អំពីការប្រព្រឹត្តទៅនៃព្រះពុទ្ធសាសនាក្នុងស្រុកទាំងមូល ដូចជាវត្តអារាម នឹងការសិក្សាជាដើម ដែលចំរើនក្តី មិនចំរើនក្តី ឬដែលមានហេតុភេទដ៏ចំឡែកដូចម្តេចក្តី ។ សេចក្តីរាយការណ៍នោះតិចក្តីច្រើនក្តី ត្រូវធ្វើជាពីរច្បាប់ គឺ ១ ច្បាប់ទុកនៅសាលាអនុគណ ១ ច្បាប់ទៀតជូនទៅលោកមេគណសម្រាប់ទុកនៅសាលាមេគណ ក្នុង ៦ ខែម្តង ក្នុងមួយឆ្នាំ ត្រូវធ្វើ ២ ដង ។

## ៤- អំពីការទទួលភារៈជាអ្នករម្ងាប់អធិករណ៍ខាងព្រះពុទ្ធសាសនា

លោកអនុគណ ដែលត្រូវទទួលភារៈជាអ្នករម្ងាប់អធិករណ៍ខាងព្រះពុទ្ធសាសនាក្នុងស្រុកតាំងមូល ត្រូវធ្វើដូចតទៅនេះគឺ :

ក- ត្រូវរំលឹកដាស់តឿនព្រះសង្ឃក្នុងស្រុកតាំងមូល មានលោកចៅអធិការវត្តជាដើម ឲ្យចេះអត់ទនគ្នា ចេះរួបរួមគ្នា ឲ្យមានសាមគ្គីរវាងគ្នានឹងគ្នា កុំឲ្យទាស់ទែងគ្នា ឲ្យចេះស្រឡាញ់រាប់អានគ្នាដូចបងប្អូន ឲ្យចេះស្អប់ខ្ពើមធុញទ្រាន់នឹងការឈ្លោះប្រកែកបែកបាក់គ្នា ដែលជាហេតុនាំឲ្យបានទុក្ខ ឲ្យចេះស្រឡាញ់ពេញចិត្តនឹងសេចក្តីសុខស្ងប់ ។

ខ- ប្រសិនបើមានអធិករណ៍ក្នុងវត្តអនុគណផ្ទាល់ អនុគណត្រូវប្រតិបត្តិតាមករណីយកិច្ចរបស់ចៅអធិការ បើមានរឿងអធិករណ៍ក្នុងវត្តដទៃដែលចៅអធិការរម្ងាប់មិនបាន ហើយគេបញ្ជូនមក ត្រូវលោកអនុគណប្រជុំគណៈសង្ឃសាលាអនុគណ ជំនុំជំរះផ្សះផ្សាឲ្យស្រុះជានឹងគ្នា បើមិនសម្រេច ត្រូវជំនុំជំរះ វិនិច្ឆ័យកាត់សេចក្តីដោយយុត្តិធម៌ បើគូវិវាទសុខចិត្តក៏ជាការស្រេច បើគូវិវាទមិនសុខចិត្តទេ ត្រូវបញ្ជូនសំណុំរឿងអធិករណ៍នោះទៅលោកមេគណ ដើម្បីឲ្យគណៈសង្ឃខេត្តសាលាមេគណជំនុំជំរះតទៅ ។

គ- របៀបជំនុំជំរះអធិករណ៍នីមួយៗ ត្រូវអនុគណបំពេញលក្ខណការ មានធ្វើសេចក្ដីកត់ហេតុជាដើម ឲ្យបានគ្រប់គ្រាន់ ។

## ៥- ការបំពេញនាយកធម៌ឲ្យមាននៅក្នុងខ្លួន

លោកអនុគណ ត្រូវឲ្យមាននាយកធម៌ គឺធម៌របស់អ្នកគ្រប់គ្រង មាន៦ យ៉ាងគឺ: ១ ហោ ជាករិយ: ឧដ្ឋាន: សំវិភាគ: ឧយោ នីង ៥ ក្នុងណា ប្រចាំនៅក្នុងខ្លួនជានិច្ច (ធម៌ទាំង ៦ នេះ បានអធិប្បាយក្នុងករណីយកិច្ចរបស់ចៅអធិការរួចហើយ) ។

## ៦- ការប្រាស្រ័យទាក់ទងនឹងលោកមេគណ

លោកអនុគណ ត្រូវមានការប្រាស្រ័យទាក់ទងនឹងលោកមេគណ ដូចជាកិច្ចការខាងអាណាចក្រ គឺចៅហ្វាយស្រុក ត្រូវប្រាស្រ័យទាក់ទងនឹងលោកចៅហ្វាយខេត្តដូច្នោះដែរគឺ :

ក- ត្រូវស្ដាប់បង្គាប់លោកមេគណជាដរាប កាលបើលោកមេគណ មានបង្គាប់តាមផ្លូវសាសនា ឬក៏តាមផ្លូវការ វៀរលែងតែលោកមេគណ មានបង្គាប់ក្នុងការផ្ដាល់ខ្លួន ដែលជាការខុសអំពីផ្លូវច្បាប់ ។

ខ- បើកិច្ចការអ្វីមួយខាងសាសនា ឬខាងរាជការ ជាកិច្ចការអនុ-គណត្រូវសម្រេច បើកិច្ចការនោះបន្តិចបន្តួច អនុគណអាចសម្រេចបាន

ដោយខ្លួនឯង បើកិច្ចការនោះធំពុំ ហួសពេកត្រូវតែសួរយោបល់ឬពិគ្រោះផ្ទាល់ជាមួយនឹងលោកមេគណជាមុនសិន ទើបសម្រេចបាន ។

គ - លោកអនុគណ ត្រូវតែរួបរួមជាមួយនឹងលោកមេគណយ៉ាងជិតស្និទ្ធ កុំឲ្យមានគំនិតបែកចេញពីលោកមេគណ ត្រូវធ្វើការរួបរួមគ្នា ទើបកិច្ចការខាងព្រះពុទ្ធសាសនា នឹងមានសេចក្ដីចំរុងចំរើនឡើងបាន ។

## ៧- ការជួយកិច្ចការរដ្ឋដែលអាចជួយបាន

លោកអនុគណ ត្រូវដឹងថាព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ គឺជាសាសនាដែលប្រជាពលរដ្ឋក្នុងប្រទេសស្ទើរតែទាំងអស់ ទទួលយកជាជាសាសនាដែលខ្លួនត្រូវគោរពត្រូវកាន់តាម ។ ដូច្នេះ ព្រះពុទ្ធ-សាសនា ជាសាសនាត្រូវជាប់ទាក់ទងជាមួយនឹងរដ្ឋ បើរដ្ឋឬប្រទេសធ្លាក់ចុះដុនដាបទន់ខ្សោយឬក្រីក្រ ឬក៏ធ្លាក់ចុះទៅជាទាសភាពរបស់បរទេស ព្រះពុទ្ធសាសនាក៏ធ្លាក់ចុះអន់កប់ទន់ទាបទៅជាមួយដែរ បើរដ្ឋឬប្រទេសរុងរឿងចំរើនឡើង ព្រះពុទ្ធសាសនាក៏រុងរឿងចំរើនឡើងដែរ ។

ដូច្នេះ កិច្ចការទាំងឡាយដែលរាជរដ្ឋាភិបាលបានចាត់ចែងធ្វើឲ្យកើតមានឡើង ដើម្បីឲ្យប្រទេសបានចំរើនរុងរឿង លោកអនុ-គណត្រូវតែយកចិត្តទុកដាក់ជាពិសេស ជួយចំពោះកិច្ចការណាដែលឥត

ទាស់ខុសនឹងច្បាប់ព្រះពុទ្ធសាសនា ដែលគួរបព្វជិតអាចជួយបាន ត្រូវតែជួយ ដូចកិច្ចកសាងសាលាសិក្សាជាដើម វៀរលែងតែកិច្ចការខ្លះដែលមានពុទ្ធបញ្ញត្តិហាមមិនឲ្យបព្វជិតធ្វើ នោះទើបមិនគួរធ្វើ ប៉ុន្តែមិនត្រូវហាមប្រាមគេមិនឲ្យធ្វើឡើយ ដោយហេតុថាកិច្ចការទាំងនោះផ្ទុយនឹងពុទ្ធបញ្ញត្តិមែន ប៉ុន្តែជាកិច្ចការដែលរាជរដ្ឋាភិបាលបានបង្កើតឲ្យមានដើម្បីឲ្យបានចំរុងចំរើនដល់ប្រទេស ។

# ការណីយកិច្ច

# នៃលោកមេគណ

លោកអនុគណណាមួយ ដែលបានទទួលការតែងតាំងជាមេគណ ត្រឹមត្រូវតាមព្រះរាជក្រមលេខ ១៦ ន.ស. ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ១៩៤៣ រួចហើយ ត្រូវបំពេញនាទីរបស់ខ្លួនក្នុងឋានៈជាមេគណ រួមជាមួយនឹងគណៈសង្ឃជាសហការី ។ មេគណនីមួយ ៗ មានអំណាចត្រួតត្រាព្រមទាំងចាត់ការផ្សេង ៗ ខាងព្រះពុទ្ធសាសនា មានកម្រឹតត្រឹមដែនតែក្នុងខេត្តនីមួយ ៗ របស់ខ្លួន ៗ មេគណនោះត្រូវបំពេញករណីយកិច្ចរបស់ខ្លួនដូចតទៅនេះគឺ:

- ការត្រួតត្រាលើលោកអនុគណគ្រប់ស្រុក
- ការពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា
- ការធ្វើសេចក្ដីរាយការណ៍អំពីព្រះពុទ្ធសាសនា
- ការទទួលភារៈជាអ្នករម្ងាប់អធិករណ៍ក្នុងព្រះពុទ្ធសាសនា
- ការបំពេញនាយកធម៌ឲ្យមាននៅក្នុងខ្លួន
- ការប្រាស្រ័យទាក់ទងនឹងសម្ដេចព្រះសង្ឃនាយក
- ការជួយកិច្ចការរដ្ឋដែលអាចជួយបាន ។

## ១- អំពីការត្រួតត្រាលើលោកអនុគណគ្រប់ស្រុក

លោកមេគណនីមួយៗ ត្រូវត្រួតត្រាលើលោកអនុគណគ្រប់ស្រុក ក្នុងខេត្តដែលខ្លួនជាអ្នកត្រួតត្រា ដូចតទៅនេះគឺ:

ក- ត្រូវរំលឹកដាស់តឿនលោកអនុគណ ឲ្យប្រតិបត្តិតាមនាទីរបស់ខ្លួនកុំឲ្យធ្វេសប្រហែស ដើម្បីកុំឲ្យលោកអនុគណភ្លេចគិតដល់ករណីយ-កិច្ចរបស់ខ្លួន ។

ខ- ត្រូវនិមន្តលោកអនុគណគ្រប់ស្រុកឲ្យមកប្រជុំ នៅវត្តលោកមេគណក្នុងមួយឆ្នាំ ឲ្យបានពីរដង គឺក្នុង ៦ ខែម្តង ។ ការប្រជុំនេះនាំឲ្យមានប្រយោជន៍ច្រើនយ៉ាងគឺ

- បានជួបមុខគ្នារឿយៗ ជាហេតុនាំឲ្យមានសាមគ្គីធម៌រវាងគ្នានឹងគ្នា
- បានរំលឹកដាស់តឿន ឬបានពិគ្រោះប្រឹក្សាគ្នាអំពីកិច្ចការផ្សេងៗ ខាងព្រះពុទ្ធសាសនា
- បានដឹងកិច្ចការខាងព្រះពុទ្ធសាសនា ដែលមានគ្រប់វត្ត ៗ.

គ- ត្រូវធ្វើបញ្ជីវត្តអារាម និងភិក្ខុ-សាមណេរគ្រប់ស្រុក ទុកក្នុងសាលាមេគណ ដើម្បីឲ្យបានដឹងថានៅក្នុងខេត្តដែលលោកមេគណជាអ្នកត្រួតត្រា ស្រុកណាមានវត្តប៉ុន្មាន មានភិក្ខុ-សាមណេរប៉ុន្មានរូប រួមទាំងអស់ក្នុងមួយខេត្តមានចំនួនប៉ុន្មាន ឯចំនួនភិក្ខុ-សាមណេរត្រូវធ្វើរាល់ឆ្នាំ ដើម្បីឲ្យបានដឹងថាក្នុងឆ្នាំណាមានច្រើន ឆ្នាំណាមានតិច ៗ

## ២- អំពីការពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា

លោកមេគណ ត្រូវពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា គ្រប់ស្រុកក្នុងខេត្តទាំងមូល ដូចតទៅនេះគឺ:

ក- កិច្ចការសិក្សាខាងព្រះពុទ្ធសាសនា ដូចជាការសិក្សាក្នុងសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ ត្រូវពិនិត្យឲ្យដឹងថា ស្រុកណាមានសេចក្ដីចំរើន ស្រុកណាមិនមានសេចក្ដីចំរើន ដែលចំរើននឹងមិនចំរើន ដោយហេតុអ្វី លោកមេគណត្រូវប្រជុំជាមួយនឹងលោកអនុគណ រកមធ្យោបាយដើម្បីធ្វើឲ្យការសិក្សាដែលមិនចំរើន ឲ្យបានចំរើនឡើង ការសិក្សាដែលបានចំរើនហើយ ឲ្យបានរឹងរឹតតែចំរើនជាភិយ្យោភាពឡើងទៀត ។

ខ- កិច្ចការផ្សេងក្រៅពីការសិក្សាខាងលើនេះ មានផ្លូវប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនាក្ដី ការរៀបចំវត្តអារាមឲ្យបានស្អាតល្អស្របទៅតាមកាលៈទេសៈក្ដី ក៏ព្រោះជាកិច្ចការខាងព្រះពុទ្ធសាសនាដែរ ។ លោកមេគណត្រូវពិនិត្យមើល ត្រូវដឹងកិច្ចការទាំងនោះ ហើយរួមកម្លាំងជាមួយនឹងលោកអនុគណ រកមធ្យោបាយធ្វើឲ្យបានចំរើនឡើង ។

គ- កិច្ចការប្រកបដោយខាងព្រះពុទ្ធសាសនា កាលបើមានការទាក់ទងជាមួយនឹងរដ្ឋាភិបាល លោកមេគណត្រូវយកចិត្តទុកដាក់ជួយញ៉ាំងកិច្ចការទាំងនោះឲ្យបានសម្រេចតាមសមត្ថភាពរបស់ខ្លួន ។

ឃ- លោកមេគណ ត្រូវមានកិច្ចមួយទៀតជាពិសេស គឺត្រូវពិនិត្យមើលដល់កិច្ចការនៃលោកអនុគណគ្រប់ស្រុក បើឃើញថាលោកអនុគណណាយកចិត្តទុកដាក់បំពេញមុខការរបស់ខ្លួនខាងព្រះពុទ្ធសាសនាឲ្យបានចំរើន ឲ្យបានសុខស្ងប់ ក្នុងស្រុករបស់ខ្លួន ត្រូវសរសើរចំពោះលោកអនុគណនោះ ដោយលិខិតឬដោយផ្ទាល់ បើអនុគណណាខ្ជិលមិនយកចិត្តទុកដាក់ មិនរវល់នឹងកិច្ចការខាងព្រះពុទ្ធសាសនា ក្នុងស្រុករបស់ខ្លួនទេ ត្រូវបន្ទោសចំពោះអនុគណនោះ ដោយលិខិតឬដោយផ្ទាល់ ។ រីឯលិខិតដែលសរសើរឬដែលបន្ទោសនោះ ត្រូវចម្លងផ្ញើទៅប្រគេនសម្តេចព្រះសង្ឃនាយក ព្រមទាំងឲ្យលោកអនុគណគ្រប់ស្រុកបានដឹងផង ដោយសម្ងាត់ ។

## ៣- អំពីការត្រូវធ្វើសេចក្តីរាយការណ៍ខាងព្រះពុទ្ធសាសនា

លោកមេគណត្រូវធ្វើសេចក្តីរាយការណ៍អំពីវត្តអារាម និងកិច្ចការផ្សេង ៗ មានការសិក្សាជាដើមខាងព្រះពុទ្ធសាសនាក្នុងខែត្រទាំងមូល ដែលបានចំរើនក្តីមិនចំរើនក្តី ឬដែលមានហេតុកេងដឹចម្លែកដូចម្តេចក្តី ។ សេចក្តីរាយការណ៍នោះនោះតិចក្តីច្រើនក្តីត្រូវធ្វើជា ២ ច្បាប់គឺ ១ ច្បាប់ទុកនៅសាលាមេគណ ១ ច្បាប់ទៀតប្រគេនទៅក្រសួងសម្តេចព្រះសង្ឃនា. យកតាមរយៈ ផ្ញើការ ។ ក្នុងសេចក្តីរាយការណ៍នោះ ជាពិសេសគឺត្រូវធ្វើឲ្យមានសេចក្តីសរសើរឬសេចក្តីបន្ទោស ចំពោះអនុគណដែលយក

ចិត្តទុកដាក់ឬមិនយកចិត្តទុកដាក់ ក្នុងកិច្ចការនៃព្រះពុទ្ធសាសនាផង ។ សេចក្តីរាយការណ៍នេះ ត្រូវធ្វើក្នុង ៦ ខែម្តង ។

## ៤– អំពីការទទួលភារៈជាអ្នករម្ងាប់អធិករណ៍

លោកមេគណ ត្រូវទទួលភារៈជាអ្នករម្ងាប់អធិករណ៍ខាងព្រះពុទ្ធសាសនាក្នុងខេត្តទាំងមូល ដូចតទៅនេះគឺ:

ក– លោកមេគណត្រូវរំលឹកដាស់តឿនលោកអនុគណគ្រប់ស្រុកក្នុងខេត្តរបស់ខ្លួន ឲ្យយកចិត្តទុកដាក់ក្នុងការរួបរួមគ្នារវាងសង្ឃនិងសង្ឃ ឲ្យមានសាមគ្គីនឹងគ្នា កុំឲ្យទាស់ទែងគ្នា ឲ្យចេះស្រឡាញ់រាប់អានគ្នាដូចបងប្អូន ឲ្យខំប្រឹងទូន្មានតាមផ្លូវធម៌ជាកិច្ចអប់រំព្រះសង្ឃ និងពុទ្ធបរិស័ទក្នុងខេត្ត ឲ្យធុញទ្រាន់ស្អប់ខ្ពើមការឈ្លោះប្រកែកបែកបាក់គ្នា ដែលជាហេតុនាំឲ្យមានទុក្ខព្រួយ ឲ្យស្រឡាញ់ពេញចិត្តតែនឹងសេចក្តីសុខស្ងប់ ។

ខ– ប្រសិនបើមានអធិករណ៍ក្នុងវត្តលោកមេគណផ្ទាល់ លោកមេគណត្រូវប្រតិបត្តិតាមករណីយកិច្ចរបស់ចៅអធិការ បើមានអធិករណ៍ក្នុងស្រុកផ្សេងៗ ដែលលោកអនុគណរម្ងាប់មិនបាន ឬវិនិច្ឆ័យហើយ គូវិវាទនៅតែពុំសុខចិត្ត ពុំព្រមស្ងប់ ហើយលោកអនុគណបានបញ្ជូនមកលោកមេគណ ៗ ត្រូវប្រជុំគណៈសង្ឃសាលាមេគណ ឲ្យជំនុំជំរះវិនិច្ឆ័យកាត់សេចក្តីដោយយុត្តិធម៌ បើអធិករណ៍នោះអាចរម្ងាប់បាននៅទីសាលាមេគណក៏ជាការស្រេច ។ បើគូវិវាទមិនសុខចិត្តទេ ត្រូវបញ្ជូនសំណុំរឿងនោះ

ទៅក្រសួងធម្មការ តាមរយៈលោកចៅហ្វាយខេត្ត ដើម្បីប្រគេនមកក្រសួងសម្តេចព្រះសង្ឃនាយក ។ ក្រសួងសម្តេចព្រះសង្ឃនាយកនឹងដាក់ឲ្យថេរសភាពិនិត្យជំនុំជំរះដោយយុត្តិធម៌តទៅ ។

## ៥– អំពីការបំពេញនាយកធម៌ឲ្យមានទៅក្នុងខ្លួន

លោកមេគណត្រូវឲ្យមាននាយកធម៌ គឺធម៌របស់អ្នកគ្រប់គ្រងមាន៦ យ៉ាងគឺ ១ ហា ជាគរិយៈ ឧដ្ឋានៈ សំវិភាគៈ ទយា ទីន ៥ ករុណា ប្រចាំទៅក្នុងខ្លួន ធម៌ទាំង ៦ យ៉ាងនេះ បានអធិប្បាយក្នុងករណីយកិច្ចរបស់លោកចៅអធិការរួចហើយ ។

## ៦– អំពីការប្រាស្រ័យទាក់ទងនឹងសម្តេចព្រះសង្ឃនាយក

លោកមេគណ ដែលត្រូវទាក់ទងនឹងសម្តេចព្រះសង្ឃនាយកផ្ទាល់ ឬនឹងក្រសួងព្រះសង្ឃនាយកនោះ គំឃើញថាធ្លាប់ប្រតិបត្តិជាយូរអង្វែងមកហើយ មិនមានការអ្វីជាចម្លែក ដែលត្រូវប្រតិបត្តិឲ្យប្លែកជាងមុន ៗ នោះឡើយ ដែលមានជាពិសេសខ្លះនោះគឺ :

ក– កិច្ចការអ្វីមួយខាងព្រះពុទ្ធសាសនា ឬខាងរដ្ឋការ ដែលកើតមានឡើងក្នុងខេត្តជាកិច្ចការទាក់ទងដល់លោកមេគណត្រូវសម្រេច បើកិច្ចការនោះបន្តិចបន្តួច លោកមេគណយល់ឃើញថាមិនមែនកិច្ចការនាំឲ្យខូចកិត្តិយសព្រះពុទ្ធសាសនាទេ អាចទទួលការខុសត្រូវលើខ្លួន ក៏

គប្បីសម្រេចដោយខ្លួនឯងបាន ប៉ុន្តែត្រូវប្រគេនដំណឹងចំពោះសម្តេចព្រះសង្ឃនាយកបានជ្រាបផង ។ ប្រសិនបើលោកមេគណគិតមិនយល់ មិនដាក់ច្បាស់ក្នុងចិត្តថាកិច្ចការនោះនឹងប្រព្រឹត្តទៅយ៉ាងណាទេ មិនហ៊ានទទួលការខុសត្រូវលើខ្លួន នោះលោកមេគណមិនត្រូវសម្រេចកិច្ចការនោះដោយខ្លួនឯងទេ ត្រូវសូមយោបល់អំពីសម្តេចព្រះសង្ឃនាយកជាមុនសិនសឹមសម្រេច ។

ខ- លោកមេគណ ត្រូវដឹងថាកិច្ចការអ្វីទាំងអស់ខាងព្រះពុទ្ធ-សាសនា ឬកិច្ចការដទៃក្រៅពីព្រះពុទ្ធសាសនា ប៉ុន្តែពាក់ព័ន្ធដល់ព្រះពុទ្ធសាសនា កិច្ចការទាំងនេះ ទើបកើតមានឡើងក្នុងខេត្ត ទោះបីមេ-គណអាចសម្រេចបានដោយខ្លួនឯងក៏ដោយ គួរប្រគេនដំណឹងចំពោះសម្តេចព្រះសង្ឃនាយកបានជ្រាបផង ព្រោះសម្តេចព្រះសង្ឃនាយកកាន់តំណែងខាងការគ្រប់គ្រងព្រះពុទ្ធសាសនា ទទួលការខុសត្រូវក្នុងរឿងព្រះពុទ្ធសាសនាទាំងមូល ។

## ៣- អំពីការជួយកិច្ចការរដ្ឋដែលអាចជួយបាន

លោកមេគណ ដែលត្រូវជួយកិច្ចការរដ្ឋនោះ ត្រូវប្រតិបត្តិដូចក្នុងករណីយកិច្ចរបស់លោកអនុគណត្រង់ទី ៧ ដែរ ។